Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ទស្សនវិស័យ ៖ ដើម្បីការបោះឆ្នោតមានអត្ថន័យ ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ

ថ្ងៃសុក្រ ៨កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤

# លទ្ធផលសង្ខេបនៃការសង្កេត
# ស្តីពី
# ការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ឆ្នាំ២០២៣

## ១. អ្នកសង្កេតការណ៍ និងវិធីសាស្ត្រសង្កេតឃ្លាំមើលការចុះឈ្មោះ

នៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ចាប់ពីថ្ងៃទី១ ដល់ ១៩ ខែតុលា ឆ្នាំ២០២៣ ខុមហ្វ្រែល បានដាក់អ្នកសង្កេតការណ៍នៅតាមបណ្តាខេត្តដែលមានចំនួន ១៤នាក់ (១ខេត្តម្នាក់) ។ ទម្រង់សង្កេតនេះ ត្រូវបានផ្ញើរមកស្នាក់ការកណ្តាល ខុមហ្វ្រែល ចំនួន ៤ដងក្នុងមួយឃុំ សង្កាត់ ក្នុងរយៈពេលនៃការចុះឈ្មោះនេះ ។

ការសង្កេតឃ្លាំមើលដំណើរការចុះឈ្មោះនេះ ខុមហ្វ្រែលមានអ្នកសង្កេតការណ៍សរុបចំនួន ១៤ ខេត្ត រួមមាន ខេត្តកំពង់ចាម ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង ពោធិ៍សាត់ បាត់ដំបង សៀមរាប តាកែវ កំពត ព្រះសីហនុ កោះកុង រតនគិរី ស្ទឹងត្រែង និងខេត្តព្រះវិហារ និងឃុំសង្កាត់សរុបចំនួន ២៨ឃុំ សង្កាត់ ។ អ្នកសង្កេតការណ៍ខុមហ្វ្រែល នៅតាម បណ្តាខេត្តបានធ្វើការចុះសង្កេតឃ្លាំមើល និងសាកសួរព័ត៌មានមួយចំនួនពីប្រជាពលរដ្ឋដែលបានទៅធ្វើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ នៅតាមបណ្តាឃុំ សង្កាត់ ។ ការពិនិត្យមើលលើទិដ្ឋភាពទូទៅ នៅការិយាល័យបោះឆ្នោត និងព័ត៌មានទាក់ទងនឹងការផ្សព្វផ្សាយ អំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត រួមទាំងធ្វើការសាកសួរទៅលើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទទួលបន្ទុកជួយក្រុមការងារចុះឈ្មោះ សមាជិកមន្ត្រីចុះឈ្មោះបោះឆ្នោត និងតំណាងអង្គការ សមាគម ផងដែរ ។

## ២. ព័ត៌មានទូទៅនៅឃុំ សង្កាត់ សម្រាប់ចុះឈ្មោះបោះឆ្នោត

**ការបិទកាលវិភាគចុះឈ្មោះបោះឆ្នោត ៖** យោងតាមការសង្កេត ឃ្លាំមើលរបស់អ្នកសង្កេតការណ៍ខុមហ្វ្រែលនៅទីតាំងចុះឈ្មោះសរុប ២៦ឃុំ សង្កាត់ ក្នុង ១៤ខេត្ត បានបង្ហាញថា មានឃុំ សង្កាត់ចំនួន ២៤ បានបិទកាលវិភាគនៃដំណើរការចុះឈ្មោះបោះឆ្នោត ដោយឡែកក្នុងនោះ ខុមហ្វ្រែលរកឃើញមានករណីមិនបិទកាលវិភាគមានចំនួន ២ឃុំ គឺ ឃុំកំពង់លាវ និងឃុំបារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង ។ កាលវិភាគដែលបានបិទនេះ ត្រូវបានមើលឃើញថា មានបិទនៅតាមសាលា



ឃុំសង្កាត់ តាមភូមិ នៅតាមសាលារៀន ទីប្រជុំជន និងកន្លែងផ្សេងទៀត ។

**ការជួបជាមួយអាជ្ញាធរឃុំសង្កាត់ពីការផ្តល់ព័ត៌មានពីការចុះឈ្មោះ** ៖ តាមរយៈការសាកសួរព័ត៌មានពីអាជ្ញាធរ និងការសង្កេតឃ្លាំមើលរបស់អ្នកសង្កេតការណ៍ គឺក្រុមការងារទទួលបន្ទុកចុះឈ្មោះបោះឆ្នោត មានមធ្យោបាយប្រហាក់ប្រហែលគ្នាជាច្រើនសម្រាប់ផ្តល់ព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន រួមមាន រយៈការប្រាប់របស់មេភូមិ មេក្រុម ការបិទប្រកាស ការប្រើប្រាស់ឧបករណ៍ឧគ្ឃោសនសព្ទ ការចែកបណ្ណព័ត៌មានជាដើម ។ កន្លែងខ្លះ បានសរសេរតាមក្តារព័ត៌មាននៅតាមសាលាឃុំ សង្កាត់នៅផ្ទះមេភូមិ បង្ហោះតាមបណ្តាញសង្គម ចងជាបដាតាមទីសាធារណៈ ឬនៅសាលារៀនជាដើម ។ រីឯអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាព តាមការពិភាក្សាជាមួយប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត ពួកគេបានលើកឡើងថា ពួកគេត្រូវបានមេភូមិ មេឃុំ ចៅសង្កាត់ប្រាប់ឱ្យទៅជួបមន្ត្រីធ្វើអត្តសញ្ញាណកម្ម និងទៅពិគ្រោះដោយផ្ទាល់។

**ការចែកលិខិតអញ្ជើញ (ប័ណ្ណព័ត៌មាន)** ៖ សម្រាប់ការចែកប័ណ្ណព័ត៌មាន អ្នកសង្កេតការណ៍បានលើកឡើងថា ក្រុមចុះឈ្មោះបោះឆ្នោតបានឱ្យមេភូមិដើរផ្សព្វផ្សាយ និងចែកតាមផ្ទះ យ៉ាងហោចឱ្យបាន ១ថ្ងៃ រឺ ២ថ្ងៃមុនក្រុមចុះឈ្មោះទៅដល់ ដើម្បីអោយប្រជាពលរដ្ឋបានដឹងជាមុន និងដើម្បីបានត្រៀមទុក ។ ដោយឡែក ចំពោះប្រជាពលរដ្ឋមួយចំនួនដែលបានចាកចេញទៅធ្វើការងារ ឬធ្វើស្រែចំការនៅឆ្ងាយពីផ្ទះក្នុងពេលចុះឈ្មោះ ក្រុមការងារឃុំ សង្កាត់ ឬក្រុមចុះឈ្មោះ បានធ្វើការផ្តល់ព័ត៌មានដល់ពួកគាត់តាមរយៈការផ្តាំផ្ញើជាមួយបង ប្អូន ឬសាច់ញាតិពីព័ត៌មានចុះឈ្មោះ រួមទាំងរក្សាទុកប័ណ្ណព័ត៌មានឱ្យពួកគេ តាមរយៈមេភូមិ ឬមេក្រុម ជាដើមផង ។

ខុមហ្វ្រែល បានសង្កេតឃើញថា លិខិតអញ្ជើញ (ប័ណ្ណព័ត៌មាន) នៅតែមានសារៈសំខាន់សម្រាប់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតពីព័ត៌មានរបស់ពួកគេ ជាពិសេសការប្រើប្រាស់ឯកសារសម្រាប់ចុះឈ្មោះ និងឯកសារសម្រាប់បោះឆ្នោត ។


លិខិតអញ្ជើញ
សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សូមអញ្ជើញឈ្មោះ   ភេទ ប្រុស   ថ្ងៃខែឆ្នាំកំណើត 09-04-1959
ខេត្ត តាកែវ   ឃុំ សីល្ហ   កូដការិ. 0938
ទីតាំងការិយាល័យ សាលាឆទានភូមិសិល្ហ   អត្តលេខ 10-41
អាសយដ្ឋាន ភូមិសីល្ហ   លេខរៀងក្នុងបញ្ជី ៧
លេខ អ.ខ 10123   ឯកសារចុះឈ្មោះ អត្តសញ្ញាណប័ណ្ណប្រភេទ៣

ប្រសិនបើពិនិត្យឃើញថា ឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់លោកអ្នកខុសពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព សូមទៅកាន់សាលាឃុំ សង្កាត់ ឬទីតាំងចុះឈ្មោះណាមួយក្នុងឃុំ សង្កាត់ខាងលើ ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣ រៀងរាល់ម៉ោងធ្វើការ ដោយភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព ដើម្បីធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។

យោងតាមព័ត៌មាននៅលើលិខិតអញ្ជើញ (ប័ណ្ណព័ត៌មាន) បានបង្ហាញថា លិខិតនោះបានបញ្ជាក់ពីព័ត៌មាននៃប្រភេទឯកសារសម្រាប់ចុះឈ្មោះ ដូចជា អត្តសញ្ញាណប័ណ្ណប្រភេទ១ ឬ២ ឬ៣ ឬ ឯ.អ និងបានបញ្ជាក់បន្ថែមថា ប្រសិនបើពិនិត្យឃើញថា ឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់អ្នកខុសពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាពសូមទៅកាន់សាលាឃុំ សង្កាត់...ដើម្បីធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីឈ្មោះបោះឆ្នោត ។ តាមរយៈការសម្ភាសន៍ប្រជាពលរដ្ឋនៅពេលចុះឈ្មោះចំនួន ១៩៦នាក់ មានតែ ៣២.១៤ភាគរយ ដែលបានដឹងថា អត្តសញ្ញាណប័ណ្ណប្រភេទ១ ឬ២ មិនអាចប្រើប្រាស់ចុះឈ្មោះ ឬទៅបោះឆ្នោតបាន ។ ***ខុមហ្វ្រែល មិនបានសង្កេតឃើញព័ត៌មានណាមួយដែលបញ្ជាក់ថា ព័ត៌មាននៃឯកសារចុះឈ្មោះបោះឆ្នោតដែលអ្នកបោះឆ្នោតមានក្នុងបញ្ជីមិនទាន់ធ្វើបច្ចុប្បន្នភាព ឬបញ្ជាក់ថា ព័ត៌មានក្នុងឯកសារនោះហួសសុពលភាពឡើយ*** ។ ករណីនេះ ខុមហ្វ្រែលបានសង្កេតឃើញកើតមានក្នុង

ពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ផងដែរ ដែលធ្វើឱ្យអ្នកមានសិទ្ធិបោះឆ្នោតបានបាត់បង់សិទ្ធិបោះឆ្នោតរបស់ខ្លួន ដោយការប្រើប្រាស់ឯកសារគ្មានសុពលភាពនេះ ។

## ៣. ស្ថានភាពកំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

### ក.បរិយាកាសនៅការិយាល័យចុះឈ្មោះបោះឆ្នោត



នៅក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតឆ្នាំ ២០២៣ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានធ្វើការសង្កេតឃ្លាំមើលដំណើរការចុះឈ្មោះនៅទីកន្លែងចុះឈ្មោះចំនួន ៨៨ដង/ទីតាំងក្នុង ២៨ឃុំ សង្កាត់ ។

**ការបិទបញ្ជីឈ្មោះបោះឆ្នោត** ៖ តាមការបញ្ជាក់របស់អ្នកឃ្លាំមើល និងសម្ភាសន៍ក្រុមការងារចុះឈ្មោះក្នុងដំណើរចុះឈ្មោះបោះឆ្នោត ឃើញថា បញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២២ បានឃើញនៅបិទតាមកន្លែងចុះឈ្មោះ ។ តាមការបញ្ជាក់បន្ថែមពីអ្នកសង្កេតការណ៍ ការសង្កេតឃ្លាំមើលចំនួន ៧៩ដង នៃការសង្កេត ៨៨ដង បានឃើញថា ការបិទបញ្ជីឈ្មោះបោះឆ្នោតមានភាពងាយស្រួលក្នុងការពិនិត្យ ក្រៅពីនោះបានលើកឡើងថា **វាមិនងាយស្រួលនោះទេ** ។ ភាពមិនងាយស្រួលនោះ គឺ ១) ទីកន្លែងបិទបញ្ជីឈ្មោះខ្លះខ្ពស់ពេកធ្វើឱ្យការឈរពិនិត្យមើលមានការពិបាក ២) ជនមានពិការភាពដោយជើង ឬជិះលើរទេះពិបាកមើល (ទោះបីនៅទីកន្លែងចុះ មានអ្នកចាំជួយពិនិត្យក៏ដោយ) ដោយសារការបិទនោះ នៅទីខ្ពស់បន្តិច សូម្បីតែអ្នកបោះឆ្នោតមានកាយសម្បទាធម្មតា ក៏ពិបាកក្នុងការពិនិត្យមើលព័ត៌មានដែរ ៣) បញ្ជីឈ្មោះនៅកន្លែងខ្លះទៀតបានបិទនៅខាងក្នុងសាលាឃុំ ដែលជាកន្លែងធ្វើការរបស់មន្ត្រី ធ្វើឱ្យប្រជាពលរដ្ឋខ្លះមិនហ៊ានដើរឆ្លងកាត់ទៅមើល ។

**វត្តមានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការជាមួយក្រុមចុះឈ្មោះបោះឆ្នោត** ៖ ក្នុងអំឡុងពេលដែលអ្នកសង្កេតការណ៍ចុះសង្កេតឃ្លាំមើល ឃើញថា សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការជាមួយក្រុមចុះឈ្មោះបោះឆ្នោត មានវត្តមាននៅជាមួយក្រុមចុះឈ្មោះ ចំនួន ៨២ដង/ទីតាំងក្នុងចំណោម ៨៨ដង/ទីតាំងសង្កេតឃ្លាំមើល ។ ហេតុផលដែលបានបញ្ជាក់ពីអវត្តមាននោះគឺ ក្រុមប្រឹក្សាមានការរវល់ផ្ទាល់ខ្លួន ។

**ភ្នាក់ងារគណបក្សនយោបាយ** ៖ ភ្នាក់ងារគណបក្សនយោបាយដែលបានចូលរួមឃ្លាំមើលដំណើរការចុះឈ្មោះ ឃើញមានវត្តមានតែភ្នាក់ងារមកពីគណបក្សប្រជាជនកម្ពុជា បានចូលរួមសង្កេតក្នុងទីតាំងការិយាល័យចុះឈ្មោះ ចំនួន ៦៧ នៃ ៨៨ដង/ទីតាំងដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលបានសង្កេតឃ្លាំមើល រីឯភ្នាក់ងារមកពីគណបក្សផ្សេងទៀត មិនឃើញវត្តមានក្នុងអំឡុងពេលអ្នកសង្កេតការណ៍ខុមហ្វ្រែលចុះនោះទេ ។

**អ្នកសង្កេតការណ៍មកពីអង្គការសមាគម** ៖ តាមការសង្កេតឃ្លាំមើលពីអ្នកសង្កេតការណ៍ខុមហ្វ្រែល បានសង្កេតឃើញវត្តមានអ្នកសង្កេតការណ៍មកពីសមាគមមានវត្តមាន ចំនួន ២២ដង នៃ ៨៨ដង/ទីតាំងចុះឈ្មោះបោះឆ្នោត គឺ សមាគម ស.ស.យ.ក ។

**ខ. វាយតម្លៃលើការចុះឈ្មោះបោះឆ្នោត**

តាមរយៈការសង្កេតឃ្លាំមើលនៅទីតាំងចុះឈ្មោះបោះឆ្នោត ជាទិដ្ឋភាពទូទៅអ្នកសង្កេតការណ៍នៅតែសង្កេតឃើញ មានប្រជាពលរដ្ឋទើបគ្រប់អាយុបោះឆ្នោតខ្លះ អ្នកទើបចុះឈ្មោះដំបូង និងអ្នកមកសុំធ្វើការកែតម្រូវឈ្មោះ មកកន្លែងទីតាំងចុះឈ្មោះជាហូរហែរ ។ តាមការបញ្ជាក់បន្ថែមពីក្រុមការងារចុះឈ្មោះ បានកត់សម្គាល់ថា អ្នកទើបគ្រប់អាយុរស់នៅក្នុងភូមិ មិនបានមកចុះឈ្មោះ គឺព្រោះអ្នកខ្លះមិនដឹង និងអ្នកខ្លះមានការរវល់មិននៅផ្ទះ ហើយថ្ងៃចុះឈ្មោះខ្លះ ដែលត្រូវចុះបែរជាមន្ត្រី ក.ច.ប សម្រាកមិនមកធ្វើការចុះឈ្មោះជូនប្រជាពលរដ្ឋនោះទេ ។

ក្រុមចុះឈ្មោះ បានចុះឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់ និងនៅតាមភូមិមួយចំនួន ។ ការចុះឈ្មោះនៅតាមភូមិមួយចំនួន ខុមហ្វ្រែល បានសង្កេតឃើញថា កន្លែងខ្លះ ក្រុមចុះឈ្មោះបានដាក់កាលវិភាគចុះពេលល្ងាចបន្ថែមទៀត ដើម្បីឱ្យប្រជាពលរដ្ឋក្នុងភូមិមានលទ្ធភាពចុះឈ្មោះ ពេលពួកគេវិលត្រឡប់មកពីការងារ ។

**គ. ព័ត៌មានពីដំណើរការចុះឈ្មោះបោះឆ្នោត**

នៅក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ខុមហ្វ្រែល បានជួបសម្ភាសន៍ប្រជាពលរដ្ឋនៅកន្លែងចុះឈ្មោះពីព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោតបានចំនួន ១៩៦នាក់ ។

**ព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោត ៖**



លទ្ធផលពីការសម្ភាសន៍ បានឱ្យដឹងថា អ្នកដែលបានដឹងពីព័ត៌មាននៃការចុះឈ្មោះបោះឆ្នោតនៅភូមិតាំងពីមុនក្រុមចុះឈ្មោះមកដល់ទីតាំងចុះ មានចំនួន ១៤១នាក់ស្មើនឹង ៧១.៩៣ភាគរយ អ្នកទើបតែដឹង ២៧នាក់ស្មើនឹង ១៣.៧៨ភាគរយ និងអ្នកមិនដឹងពីមុនមក ២៨នាក់ស្មើនឹង ១៤.២៩ភាគរយ។

**មធ្យោបាយផ្សព្វផ្សាយព័ត៌មានពីការចុះឈ្មោះបោះឆ្នោត ៖** អ្នកសម្ភាសន៍បានបញ្ជាក់បន្ថែមទៀតថា សម្រាប់ព័ត៌ពីការចុះឈ្មោះបោះឆ្នោតដែលគាត់ទទួលបាន គឺពួកគាត់ដឹងតាមរយៈ ការផ្តល់ព័ត៌មានដោយមេភូមិ មេឃុំ ចៅសង្កាត់ សមាជិកក្រុមគ្រួសារ ការបិទប្រកាស ការចងបដាតាមដងផ្លូវ ការចែកប័ណ្ណព័ត៌មាន និងការប្រើប្រាស់ឧគ្ឃោសនសព្ទផងដែរ ។ អ្វីដែលចាប់អារម្មណ៍ទាក់ទងជាមួយការផ្សព្វផ្សាយព័ត៌មានពីការចុះឈ្មោះបោះឆ្នោតដោយការប្រើប្រាស់ឧគ្ឃោសនសព្ទ អ្នកផ្តល់បទសម្ភាសន៍បានសម្តែងមតិចាប់អារម្មណ៍ថា ការចាក់ផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយ គឺខ្វះខាតវិធីសាស្ត្រក្នុងការផ្តល់ព័ត៌មានឱ្យបានពេញលេញ ព្រោះពួកគេបានប្រើប្រាស់ម៉ូតូចល័តចាក់ឧគ្ឃោសនសព្ទដោយមិនបានឈប់ស្ងៀមនោះទេ មានន័យថា *ខាងដើមបានស្តាប់មតិខ្លះក៏ដាច់ន័យ ដោយម៉ូតូធ្វើដំណើរទៅហួស រីឯអ្នកស្តាប់បន្ត ពេលម៉ូតូទៅដល់ក៏មិនបានដឹងច្បាស់ថា ខាងដើមគេនិយាយពីអ្វីនោះដែរ សរុបស្តាប់មិនបានអត្ថន័យពេញលេញនៃការផ្សព្វផ្សាយព័ត៌មាននោះឡើយ ។*




**ព័ត៌មានទាក់ទងឯកសារចុះឈ្មោះបោះឆ្នោត** ៖ ទាក់ទងជាមួយព័ត៌មាននេះ ប្រជាពលរដ្ឋត្រូវបានសាកសួរបន្ថែមពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ថា តើអ្នកបានដឹងពីព័ត៌មានពី អ.ខ ប្រភេទ១ និង ២ ដែលមិនអាចប្រើប្រាស់សម្រាប់ចុះឈ្មោះ ឬបោះឆ្នោតបានដែរឬទេ? ជាលទ្ធផលអ្នកផ្តល់ចម្លើយចំនួន ៦៣នាក់ ស្មើនឹង ៣២.១៤ភាគរយនៃ ១៩៦នាក់បញ្ជាក់ថា ពួកគេធ្លាប់បានដឹងអំពីព័ត៌មាននេះ គឺមិនអាចប្រើបានសម្រាប់ចុះឈ្មោះ ឬបោះឆ្នោត ។ ហើយអ្វីដែលពួកគាត់ដឹងពីព័ត៌មាននេះ គឺតាមរយៈផ្តល់ព័ត៌មានដោយមេភូមិ មេឃុំ ចៅសង្កាត់ ក្រុមចុះឈ្មោះបោះឆ្នោត មេប៉ុស្តិ៍ ការបិតខិតប័ណ្ណអំពីឯកសារដែលអាចប្រើប្រាស់បាន និងមើលតាមប្រព័ន្ធផ្សព្វផ្សាយនានា ។

**ឃ. ចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធក្នុងដំណើរការចុះឈ្មោះ**

អ្នកសង្កេតការណ៍សង្កេត ឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោត បានធ្វើការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធនៃការចុះឈ្មោះបោះឆ្នោតចំនួន ៨២នាក់ពីចំណាប់អារម្មណ៍របស់ពួកគេ ។ ជាលទ្ធផលបានបង្ហាញថា ៖

**មន្ត្រី គ.ច.ប** ៖ ការចុះឈ្មោះនេះ គឺមានភាពល្អប្រសើរក្នុងការរៀបចំ មិនមានបញ្ហាអ្វីនោះទេ ។

**ភ្នាក់ងារគណបក្សនយោបាយ** ៖ អ្នកមកចុះឈ្មោះ ពួកគេមានចិត្តសប្បាយ និងសង្ឃឹមថានឹងមានសិទ្ធិបោះឆ្នោតគ្រប់អាណត្តិ ។ ជាមួយគ្នានេះ ពួកគេបានសំណូមពរដល់លោកមេឃុំ ចៅសង្កាត់ និងមេភូមិ ធ្វើការផ្សព្វផ្សាយបន្ថែមទៀតអំពីដំណើរការចុះឈ្មោះបោះឆ្នោតឱ្យបានល្អប្រសើរ ។

**អ្នកសង្កេតការណ៍សមាគម** ៖ ពួកគេបានលើកឡើងថា ការចុះឈ្មោះបោះឆ្នោតមានភាពល្អប្រសើរក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ។ ពលរដ្ឋបានយល់ដឹងច្រើនអំពីនីតិវិធីនៃដំណើរការចុះឈ្មោះបោះឆ្នោត ។ ពួកគេបានសំណូមពរឱ្យភាគីពាក់ព័ន្ធជួយផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ ។

**ចំណាប់អារម្មណ៍អ្នកសង្កេតការណ៍ខុមហ្វ្រែល** ៖ ការចុះឈ្មោះបោះឆ្នោតមានដំណើរការល្អ ពលរដ្ឋមកចុះឈ្មោះមានភាពងាយស្រួល និងមកចុះឈ្មោះច្រើន ។ ការសង្កេតឃើញថា មន្ត្រី គ.ច.ប បានទទួលរាក់ទាក់យ៉ាងល្អដល់ប្រជាពលរដ្ឋ ថ្វីបើដំណើរការចុះឈ្មោះនៅក្នុងរដូវភ្ជុំបិណ្ឌ ក៏ប៉ុន្តែនៅកន្លែងខ្លះ ពួកគាត់នៅតែទៅធ្វើការនៅកន្លែងចុះឈ្មោះជានិច្ច ។ មន្ត្រី គ.ច.ប មេឃុំ ចៅសង្កាត់ និងអាជ្ញាធរភូមិ បានផ្តល់ព័ត៌មានពីដំណើរការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ។ ចំពោះអ្នកសង្កេតការណ៍មកពីភាគីពាក់ព័ន្ធ មិនឃើញមានការចូលរួមច្រើននោះឡើយ គឺមានតែភ្នាក់ងារមកពីគណៈបក្សប្រជាជនកម្ពុជានៅកន្លែងខ្លះ និងអ្នកសង្កេតការណ៍មកពីសមាគម ស.ស.យ.ក នៅកន្លែងខ្លះដែលបានចូលរួមសង្កេត ។ ទាក់ទងការផ្សព្វផ្សាយ និងផ្តល់ព័ត៌មានវិញ គឺក្រុមចុះឈ្មោះ សហការជាមួយអាជ្ញាធរភូមិ ឃុំ សង្កាត់ ប្រើប្រាស់ឧគ្ឃោសនសព្ទពីរ ឬបីថ្ងៃ នៅក្នុងមូលដ្ឋាន ពលរដ្ឋខ្លះ គាត់មិនបានដឹង និងចាប់អារម្មណ៍ថា គេប្រើឧគ្ឃោសនសព្ទដើម្បីអ្វី ។ ទោះបីមានមេភូមិ មេក្រុមបានដើរហៅពលរដ្ឋអោយចុះឈ្មោះ ប៉ុន្តែប្រជាពលរដ្ឋខ្លះ មិនទាន់

យល់ច្បាស់ពីការចុះឈ្មោះបោះឆ្នោតដើម្បីអ្វីនោះដែរ ។ បន្ថែមពីនេះក៏មានអាជ្ញាធរបានធ្វើការស្វះស្វែងទៅផ្តល់ព័ត៌មានចំពោះអ្នកគ្រប់អាយុចុះឈ្មោះ បើសិនជាអាជ្ញាធរមើលមិនទាន់ឃើញមកចុះឈ្មោះនៅឡើយ ។

## ៤. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត

**ការផ្ទៀងផ្ទាត់ឈ្មោះដូចគ្នា/ស្ទួនលើបញ្ជីឈ្មោះបោះឆ្នោត ៖**




ឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតចំនួនជាង ៩.៨៧១.៤៩៥ ឈ្មោះ មានឈ្មោះចំនួន ១៤ឈ្មោះជាឈ្មោះស្ទួនគ្នា/ដូចគ្នា ដោយផ្អែកលើលក្ខខណ្ឌចំនួន ៤ គឺ ទី១ លេខសម្គាល់នៃការបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោត (អ.ខ ឬឯ.អ) ទី ២ ព័ត៌មានពីភេទ និងទី៣ គឺព័ត៌មានពីថ្ងៃខែឆ្នាំកំណើត និងទី៤ គឺនាមត្រកូល និងនាមខ្លួន ។ ចំនួនឈ្មោះស្ទួននេះ បើគិតពីអ្នកមានសិទ្ធិបោះឆ្នោត មានចំនួន ៧នាក់ ។

បើផ្អែកលើលក្ខខណ្ឌត្រឹមលេខសម្គាល់នៃការបញ្ជាក់អត្តសញ្ញាណអ្នកមានសិទ្ធិបោះឆ្នោត (អ.ខ ឬ ឯ.អ) ឈ្មោះក្នុងបញ្ជីចំនួន ១៥,៨២០លេខសម្គាល់ រកឃើញថា ជាឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតមានលេខសម្គាល់ អ.ខ ឬ ឯ.អ ស្ទួនគ្នា/ដូចគ្នា តួលេខនេះ មានការថយចុះបើប្រៀបធៀបជាមួយបញ្ជីឆ្នាំ២០២២ មានចំនួន ១៦,៣៦៩លេខសម្គាល់ ។

**ឈ្មោះដូចគ្នា/ស្ទួនធៀបទីតាំង៖** ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៧រូប (ឬ ១៤ឈ្មោះ) ដែលមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២៣ ឃើញថា ឈ្មោះខ្លះមានស្ទួនក្នុងការិយាល័យតែមួយ ខ្លះមានស្ទួនក្នុងឃុំតែមួយតែខុសការិយាល័យ ខ្លះទៀតស្ទួនក្នុងខេត្តតែខុសតែឃុំសង្កាត់ និងខ្លះទៀតស្ទួនខុសខេត្តគ្នាតែម្តង (សូមពិនិត្យឯកសារភ្ជាប់ជាមួយ) ។

**ការប្រើប្រាស់ឯកសារសម្រាប់ចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត**




ខុមហ្វ្រែល បានសិក្សាឃើញថា ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៩,៨៧១,៤៩៥ឈ្មោះ នៅតែមានអ្នកប្រើប្រាស់ឯកសារ អ.ខ ប្រភេទទី១ ចំនួន ៣៩១,៥៩៦ឈ្មោះស្មើនឹង ៣.៩៧ភាគរយ អ.ខ ប្រភេទទី២ ចំនួន ២៣៨,៧១០ឈ្មោះស្មើនឹង ២.៤២ភាគរយ អ.ខ ប្រភេទទី៣ ចំនួន ៨,៣០៨,៩៦៤ឈ្មោះស្មើនឹង ៨៤.១៧ភាគរយ និងឯកសារ អ.ខ ប្រភេទថ្មីចំនួន ៤២៣,៤៨៣ឈ្មោះ ស្មើនឹង ៤.២៩ភាគរយ និងឯកសារ ឯ.អ សរុបចំនួន ៥០៨,៧៤២ឈ្មោះស្មើនឹង ៥.១៥ភាគរយ ។

បើធ្វើបញ្ចូលឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ប្រភេទ១ និង២ សរុបមានចំនួន ៦៣០,៣០៦ឈ្មោះ ស្មើនឹង ៦.៣៩ភាគរយនៃឈ្មោះសរុបក្នុងបញ្ជីឈ្មោះឆ្នាំ២០២៣ (អ.ខ ប្រភេទទី១ ចំនួន ៣៩១,៥៩៦ឈ្មោះ និងប្រភេទទី២ ចំនួន ២៣៨,៧១០ឈ្មោះ) ។

ទោះយ៉ាងណាឯកសារចំនួន ១១.៥ភាគរយ (រួមបញ្ចូល អ.ខ ប្រភេទ១ /២ និង ឯ.អ) ឈ្មោះនៃឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ត្រូវការចាំបាច់ធ្វើបច្ចុប្បន្នភាពឯកសារបន្តទៀត ដើម្បីឱ្យស្របលក្ខខណ្ឌទាំងឡាយទាក់ទងបញ្ជីឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។ តួលេខដែលមានការព្រួយបារម្ភក្នុងការប្រើប្រាស់ឯកសារនេះ ឃើញថា មានការធ្លាក់ចុះតិចតួចចំនួន ០.៣ភាគរយ បើធៀបជាមួយតួលេខក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២២ (ចំនួន ១១.៨ភាគរយ)កន្លងមក ។ បើយើងពិនិត្យមើលលើការប្រើឯកសារ ឯ.អ រវាងបញ្ជីឆ្នាំ២០២២ និង ឆ្នាំ២០២៣ ឃើញថា តួលេខឆ្នាំ២០២៣ មានកើនឡើងចំនួន ១៣,៣០០ឈ្មោះ (ឯកសារ ឯ.អ សរុបចំនួន ៤៩៥,៤៤២ឈ្មោះ នៅឆ្នាំ២០២២) ។

**ខុមហ្វ្រែល នូវតែមិនទាន់សង្កេតឃើញលើព័ត៌មាន ឬការបញ្ជាក់ណាមួយពីភាគីពាក់ព័ន្ធ បញ្ជាក់ថា ឯកសារ អ.ខ ប្រភេទទី១ និងទី២ ៦.៣៩ភាគរយជាអ្នកបោះឆ្នោតផ្សេងគ្នាដែលបានប្រើប្រាស់ ឬជាអ្នកបោះឆ្នោតតែម្នាក់ ដែលបានប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ។**

## ៦. អនុសាសន៍សម្រាប់កែលម្អបន្ត

យោងតាមរបាយការណ៍ បានពីការសង្កេតឃ្លាំមើល និងការរកឃើញក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែល សូមជូននូវអនុសាសន៍មួយចំនួន ដូចខាងក្រោម ៖

- យោងលើការសង្កេតឃ្លាំមើល (ខ្លឹមសារលម្អិតនៅខាងលើ) កន្លែងខ្លះបានបិទបញ្ជីឈ្មោះបោះឆ្នោតមិនបង្កភាពងាយស្រួលដល់អ្នកបោះឆ្នោតទៅពិនិត្យ និងផ្ទៀងផ្ទាត់ ជាពិសេសជនមានពិការភាព ។ ករណីនេះ សូមផ្តល់ជាអនុសាសន៍ ស្នើ គ.ជ.ប គួរតែណែនាំបន្ថែមដល់មន្ត្រីទទួលបន្ទុករៀបចំចុះឈ្មោះបោះឆ្នោតក្នុងការបិទផ្សព្វផ្សាយបញ្ជីឈ្មោះបោះឆ្នោតនៅទីតាំងចុះឈ្មោះ និងកាលវិភាគចុះឈ្មោះ **ធ្វើយ៉ាងណាផ្តល់លទ្ធភាពងាយស្រួលដល់ប្រជាពលរដ្ឋ ជាពិសេសជនមានពិការភាព**ថែមទៀត ។
- ការជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋ រួមទាំងកិច្ចពិភាក្សា បានរកឃើញថា ការផ្តល់ព័ត៌មានតាមរយៈឧគ្ឃោសសព្ទ ក៏ជាផ្នែកមួយសំខាន់ផងដែរក្រៅពីមធ្យោបាយផ្តល់ព័ត៌មានតាមរយៈមេភូមិ ឬសាច់ញាតិ ឬមធ្យោបាយផ្សេងទៀត ។ ករណីនេះ ខុមហ្វ្រែល សូមផ្តល់អនុសាសន៍ដល់ គ.ជ.ប គួរតែបន្ត និងពង្រឹងការផ្តល់ព័ត៌មានតាមឧគ្ឃោសនសព្ទនេះទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមភូមិ ក៏ប៉ុន្តែ **ត្រូវចាក់ផ្សាយនៅទីតាំងណាមួយយ៉ាងហោចឱ្យបានពីរដងនៃដំណឹងដែលត្រូវប្រាប់** ចាំធ្វើដំណើរបន្ត ។
- ការចែកលិខិតអញ្ជើញ(ប័ណ្ណព័ត៌មាន) តាមរយៈការផ្ញើឯកសារ នៅក្រុមចុះឈ្មោះបោះឆ្នោត ឬអាជ្ញាធរឃុំសង្កាត់ ក៏នៅតែមានប្រសិទ្ធិភាព ខុមហ្វ្រែល សូមផ្តល់ជាយោបល់ថា ការរក្សាទុកនៅមេភូមិ មេក្រុម សាច់ញាតិ ឬអ្នកជិតខាងនៅតែមានប្រសិទ្ធិភាព ។ **គ.ជ.ប គួរតែធ្វើសេចក្តីណែនាំ ឬចែងក្នុងនីតិវិធី ដើម្បីឱ្យក្រុមចុះឈ្មោះ ឬភាគីទទួលខុសត្រូវមានវិធានការដូចគ្នា និងឱ្យបានគ្រប់ទីកន្លែងចុះឈ្មោះបោះឆ្នោត** ។
- លិខិតអញ្ជើញសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត តាមការសង្កេតឃ្លាំមើល តាមរយៈកម្មវិធីកិច្ចពិភាក្សា និងសម្ភាសន៍ប្រជាពលរដ្ឋ ឃើញថា គ.ជ.ប បានខិតខំប្រើប្រាស់មធ្យោបាយក្នុងការចែកជូនដល់ប្រជាពលរដ្ឋ តែទោះជាយ៉ាងណា ខុមហ្វ្រែល សង្កេតឃើញថា ព័ត៌មាននៅលើលិខិតអញ្ជើញនោះខ្វះខាតការបញ្ជាក់ពីប្រភេទឯកសារអស់សុពលភាពមិនអាចយកទៅបោះឆ្នោតបានឱ្យច្បាស់ ។ ករណីនេះ ខុមហ្វ្រែល សូមផ្តល់ជាអនុសាសន៍ថា លិខិតអញ្ជើញសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គួរតែសរសេរបញ្ជាក់ពី**ព័ត៌មានហួសសុពលភាពក្នុងបញ្ជីឈ្មោះបោះឆ្នោតឱ្យបានច្បាស់** និងងាយយល់ ឧទាហរណ៍ខ្លឹមសារ «ឯកសារចុះឈ្មោះ **អត្តសញ្ញាណប័ណ្ណប្រភេទ១** នេះ **មិនអាចប្រើប្រាស់ ឬកាន់ទៅបោះឆ្នោតក្នុងថ្ងៃបោះឆ្នោតបានទេ ឬឯកសារនេះបានហួសសុពលភាពហើយ** សូមទៅ...» ។
- តាមរយៈការសិក្សាលើបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២៣ រកឃើញថា អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៦.៣៩ភាគរយឈ្មោះ ជាអ្នកបោះឆ្នោតដែលប្រើប្រាស់ឯកសារចុះឈ្មោះ អ.ខ ប្រភេទ១ និង ២ ។ ខុមហ្វ្រែល សូមសម្តែងការព្រួយបារម្ភពីលទ្ធភាពនៃការបាត់បង់សិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោតខាងមុខ ។ ខុមហ្វ្រែល **ស្នើផ្តល់ជាយោបល់ជូន គ.ជ.ប គួរតែចេញព័ត៌មានតាមរយៈលិខិតអញ្ជើញ (ប័ណ្ណព័ត៌មាន) ចំពោះឯកសារ អ.ខ ប្រភេទ១ ឬ ២ និង ឯ.អ ជូនទៅអ្នកបោះឆ្នោត ដើម្បីរំលឹកពួកគេថា ព័ត៌មាននៅក្នុងបញ្ជីឈ្មោះរបស់គេ ហួសសុពលភាព ដើម្បីអ្នកបោះឆ្នោតមានលទ្ធភាពទៅធ្វើឯកសារថ្មី និងផ្លាស់ប្តូរ ។ ជាមួយគ្នានេះ គ.ជ.ប គួរមានសេចក្តីណែនាំ ឬវិធានការជាក់លាក់ប្រាកដ និងលាយលក្ខអក្សរទៅអាជ្ញាធរភូមិ ឃុំ សង្កាត់ ដើម្បីសហការផ្តល់ជាព័ត៌មានទាំងនេះឱ្យដល់អ្នកបោះឆ្នោតនៅក្នុងដែនដីរបស់ពួកគេ** ។
- តាមរយៈការសិក្សាលើបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២៣ រកឃើញថា អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៦.៣៩ភាគរយឈ្មោះ ជាអ្នកបោះឆ្នោតដែលប្រើប្រាស់ឯកសារចុះឈ្មោះ អ.ខ ប្រភេទ១ និង

**២ ។ ខុមហ្វ្រែល ស្នើដល់ គ.ជ.ប គួរតែរកទិន្នន័យមកបញ្ជាក់ឈ្មោះនៅក្នុងបញ្ជីឈ្មោះឆ្នាំ២០២៣ ពីទិន្នន័យអ្នកមានសិទ្ធិបោះឆ្នោត ដែលប្រើប្រាស់ឯកសារចុះឈ្មោះ អ.ខ ប្រភេទ១ និង២ តើវាមានឈ្មោះនៅក្នុងចំណោមអ្នកប្រើប្រាស់ឯកសារ ឯ.អ ដែរទេ ដើម្បីធ្វើយ៉ាងណាកុំឱ្យបញ្ជីឈ្មោះប៉ោង ។**

- ការសិក្សាលើបញ្ជីឈ្មោះស្ទួន ឬព័ត៌មានដូចគ្នា ខុមហ្វ្រែល បានរកឃើញចំនួន ១៤ឈ្មោះ ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ខុមហ្វ្រែល សូមផ្តល់ជូន គ.ជ.ប សិក្សា និងពិចារណាលុបចោលឈ្មោះដែលបានរកឃើញនោះ បើសិនជាផ្ទៀងផ្ទាត់រកឃើញថាស្ទួនពិតប្រាកដ (ដូចមានក្នុងឧបសម្ព័ន្ធទី១) ។
- ខុមហ្វ្រែល នៅតែស្នើ គ.ជ.ប គួរតែបន្តជជែកជាមួយតំណាងរាស្ត្រ ឬរដ្ឋសភាជាតិ ឬរដ្ឋាភិបាលពីបញ្ហារាំងស្ទះក្នុងដំណើរការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋរស់នៅ ឬចំណាកស្រុកនៅក្រៅប្រទេស ជូនពួកគេដើម្បីធានាពីសិទ្ធិរបស់ពួកគេដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងការទទួលខុសត្រូវរបស់ គ.ជ.ប ដែលបានចែងនៅក្នុងច្បាប់ ។
- ខុមហ្វ្រែល នៅតែស្នើ គ.ជ.ប ដកចេញនូវនីតិវិធីនៃការតម្រូវឱ្យស្ថាប័នស្នើសុំចុះឈ្មោះអ្នកសង្កេតការណ៍ ធ្វើការបញ្ជាក់ពីស្ថានភាពថវិកា (ការចំណាយ និងប្រភពចំណូលរបស់ស្ថាប័ន) ទាក់ទងការសង្កេតការណ៍នេះ ព្រោះថា ក្នុងច្បាប់មិនមានកាតព្វកិច្ចចែងឱ្យសង្គមស៊ីវិលត្រូវរាយការណ៍ឡើយ ។

## ឧបសម្ព័ន្ធទី១ ៖ បញ្ជីឈ្មោះស្ទួន/ដូចគ្នា

| លេខរៀងក្នុងបញ្ជី | លេខកូដខេត្ត | លេខកូដឃុំ | លេខកូដការិយាល័យ | ប្រភេទ | លេខអត្តញ្ញាណ | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឈ្មោះឯកសារ |
|---|---|---|---|---|---|---|---|---|
| 276 | 07 | 036 | 0366 | អ.ខ ទី១ | 110252896 | ប្រុស | 06/06/1986 | 070360366 |
| 45 | 07 | 045 | 0502 | អ.ខ ទី៣ | 110252896 | ប្រុស | 06/06/1986 | 070450502 |
| 203 | 07 | 057 | 0611 | អ.ខ ទី២ | 110387308 | ស្រី | 02/10/1986 | 070570611 |
| 209 | 07 | 057 | 0613 | អ.ខ ទី៣ | 110387308 | ស្រី | 02/10/1986 | 070570613 |
| 49 | 08 | 083 | 0886 | អ.ខ ទី៣ | 050147835 | ស្រី | 12/12/1980 | 080830886 |
| 62 | 14 | 078 | 1210 | អ.ខ ទី១ | 050147835 | ស្រី | 12/12/1980 | 140781210 |
| 450 | 10 | 017 | 0191 | អ.ខ ទី៣ | 070002503 | ប្រុស | 10/10/1972 | 100170191 |
| 314 | 12 | 076 | 1223 | អ.ខ ទី៣ | 070002503 | ប្រុស | 10/10/1972 | 120761223 |
| 460 | 12 | 102 | 1718 | អ.ខ ប្រភេទថ្មី | 100732066 | ប្រុស | 22-06-1990 | 121021718 |
| 425 | 12 | 102 | 2190 | អ.ខ ប្រភេទថ្មី | 100732066 | ប្រុស | 22-06-1990 | 121022190 |
| 167 | 20 | 080 | 0920 | អ.ខ ទី៣ | 090564951 | ស្រី | 01/12/1995 | 200800920 |
| 526 | 20 | 080 | 0920 | អ.ខ ទី៣ | 090564951 | ស្រី | 01/12/1995 | 200800920 |
| 160 | 25 | 006 | 0106 | អ.ខ ទី៣ | 060946987 | ប្រុស | 03/05/1985 | 250060106 |
| 161 | 25 | 006 | 0106 | អ.ខ ទី១ | 060946987 | ប្រុស | 03/05/1985 | 250060106 |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ៧៣២ **គ.ជ.ប**

ខុមហ្វ្រែល
ទទួល
លេខ ២៤
ថ្ងៃ 8-07-2024
ម៉ោង

**ជម្រាបមក**
**លោក គឹម ឈន នាយកប្រតិបត្តិ**
**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

**កម្មវត្ថុ** : លទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លើរបាយការណ៍ស្ដីពីលទ្ធផលសង្កេតនៃការចុះឈ្មោះ និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ របស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)។

**យោង** : លិខិតលេខ ៥៥/២៤ គ.ប.ស.យ របស់ខុមហ្វ្រែល ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤។

តបតាមកម្មវត្ថុ និងយោងខាងលើ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមជម្រាប **លោកនាយកប្រតិបត្តិ** ជ្រាបថា បន្ទាប់ពីបានទទួលរបាយការណ៍សង្ខេបស្ដីពីការសង្កេតនៃការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីបោះឆ្នោត ឆ្នាំ២០២៣ នៅតាមឃុំ សង្កាត់ចំនួន ២៨ នៃខេត្តចំនួន ១៤ រួមមានខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពត ខេត្តកោះកុង ខេត្តព្រះវិហារ ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ ខេត្តរតនគិរី ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ របស់ខុមហ្វ្រែលរួចមក គ.ជ.ប បានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់យ៉ាងយកចិត្តទុកដាក់លើករណីដែលខុមហ្វ្រែលបានរកឃើញ ហើយសូមធ្វើការឆ្លើយតបដូចខាងក្រោម៖

**១. ករណីខ្លឹមសារព័ត៌មាននៅលើលិខិតអញ្ជើញ**

លិខិតអញ្ជើញដែល គ.ជ.ប បានផលិតគឺក្នុងគោលបំណងជូនដំណឹងដល់ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ និងបានប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ប្រភេទចាស់ដែលហួសសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ក្នុងការចុះឈ្មោះបោះឆ្នោតកន្លងមក **ដើម្បីមកធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតតាម អ.ខ ប្រភេទថ្មីដែលមានសុពលភាព ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣**។ ម្យ៉ាងវិញទៀត ក៏សម្រាប់ជូនដំណឹងដល់អ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២២ ដែលបានប្រើប្រាស់ អ.ខ ដែលមានសុពលភាពក្នុងការចុះឈ្មោះបោះឆ្នោតកន្លងមក **ដើម្បីទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ ឬ/និងទិន្នន័យរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ប្រសិនបើមានការកត់ត្រាមិនបានត្រឹមត្រូវតាម អ.ខ របស់គាត់ សាមីខ្លួនក៏អាចស្នើសុំកែតម្រូវក្នុងអំឡុងពេលនេះបានផងដែរ ។**

ចំពោះខ្លឹមសារ ទិន្នន័យ និងព័ត៌មាននានារបស់អ្នកបោះឆ្នោតនៅលើខិតអញ្ជើញ គ.ជ.ប បានបញ្ជាក់ការជូនដំណឹងដាច់ដោយឡែកពីគ្នា រវាងអ្នកបោះឆ្នោតដែលបានប្រើប្រាស់ អ.ខ ប្រភេទ១

ប្រភេទ២ ឬ ឯ.អ ព្រមទាំង អ.ខ ប្រភេទ៣ និងប្រភេទថ្មីដែលមានតែមប្រើ Hologram។ ដូចនេះករណី ដែលខុមហ្វ្រែល បានកំណត់បញ្ហាលើខ្លឹមសារព័ត៌មាននៅលើលិខិតអញ្ជើញដែល គ.ជ.ប ផលិតនេះ គឺជាការកំណត់ដែលធ្វើឡើងដោយមិនបានត្រួតពិនិត្យគ្រប់ជ្រុងជ្រោយនៅឡើយ។

### ២. ករណីស្ទួនលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណ

ករណីនេះ គ.ជ.ប បានសិក្សាតាមរយៈការផ្ទៀបនឹងលក្ខខណ្ឌដូចគ្នាដែលខុមហ្វ្រែលបានប្រើប្រាស់ ឃើញថាមានចំនួន ១៥,៧៥៨ លេខសម្គាល់។ ប៉ុន្តែប្រសិនបើផ្ទៀបតាមលក្ខខណ្ឌ អ.ខ ប្រភេទ១ ជាមួយ អ.ខ ប្រភេទ១ អ.ខ ប្រភេទ២ ជាមួយ អ.ខ ប្រភេទ២ អ.ខ ប្រភេទ៣ ជាមួយ អ.ខ ប្រភេទ៣ និង ឯ.អ ជាមួយ ឯ.អ ឃើញថាមានចំនួនត្រឹមតែ ១,២៩៣ លេខសម្គាល់តែប៉ុណ្ណោះ ដោយក្នុងនោះ៖

- អ.ខ ប្រភេទ១ ចំនួន ២០៧ លេខសម្គាល់
- អ.ខ ប្រភេទ២ ចំនួន ៣១០ លេខសម្គាល់
- អ.ខ ប្រភេទ៣ ចំនួន ៤០៥ លេខសម្គាល់
- ឯ.អ ចំនួន ៣៤៥ លេខសម្គាល់
- អ.ខ ប្រភេទថ្មី ចំនួន ២៦ លេខសម្គាល់។

តាមរយៈការផ្តល់របាយការណ៍ស្តីពីការលទ្ធផលនៃការសង្កេត និងសវនកម្មបញ្ជីបោះឆ្នោត របស់ខុមហ្វ្រែលកន្លងមក ករណីស្ទួនលេខ អ.ខ ឬ ឯ.អ នេះ គ.ជ.ប ក៏ធ្លាប់បានសិក្សាឃើញថាកំហុសខ្លះមកពី៖ លេខអត្តសញ្ញាណប័ណ្ណដូចគ្នា ប៉ុន្តែទិន្នន័យផ្សេងគ្នា និងករណីខ្លះទៀតជាកំហុសរបស់ការចុះឈ្មោះបោះឆ្នោតក្នុងពេលអនុវត្តដំណើរការចុះឈ្មោះ ដូចជា៖ ថតឯកសារខុស បញ្ចូលលេខID ឬ/និង ទិន្នន័យខុស ថតមើលមិនច្បាស់ (ID 000000000 អ.ខ) និង (ID 0000000 ឯ.អ) ជាដើម។ ចំពោះករណីស្ទួនលេខ អ.ខ ឬ ឯ.អ ដែល គ.ជ.ប បានរកឃើញចំនួន ១,២៩៣ លេខសម្គាល់ ដោយការផ្ទៀបតាមលក្ខខណ្ឌដូចបានជម្រាបខាងលើ គ.ជ.ប ត្រូវការពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាលម្អិត មុននឹងធ្វើការឆ្លើយតបជូនខុមហ្វ្រែល។

### ៣. ករណីឈ្មោះ និងទិន្នន័យស្ទួន

ករណីឈ្មោះស្ទួនដែលខុមហ្វ្រែលបានរកឃើញចំនួន ១៤ ឈ្មោះ គ.ជ.ប បានរកឃើញថាមាន ៤ ឈ្មោះ គឺស្ទួនពិតប្រាកដ ដូចនេះ គ.ជ.ប នឹងធ្វើការលុបចំនួន ២ ឈ្មោះចេញ ដោយរក្សាទុកតែឈ្មោះដែលបានចុះនៅក្នុងឃុំ សង្កាត់ចុងក្រោយក្នុងអំឡុងពេលដំណើរពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤។ ដោយឡែក ឈ្មោះក្រៅពីនេះគឺមិនមែនជាឈ្មោះស្ទួនឡើយ ហើយករណីទាំងនេះ គ.ជ.ប ក៏ធ្លាប់បានឆ្លើយបំភ្លឺលើរបាយការណ៍ស្តីពីការសង្កេត និងសវនកម្មបញ្ជីបោះឆ្នោតរបស់ខុមហ្វ្រែល រៀងរាល់ឆ្នាំផងដែរ។

ទោះជាយ៉ាងណាក៏ដោយ គ.ជ.ប សូមថ្លែងអំណរគុណចំពោះខុមហ្វ្រែល ដែលតែងតែសហការ ដោយបានធ្វើការសង្កេត និងសវនកម្មលើបញ្ជីបោះឆ្នោតរបស់ គ.ជ.ប ជាបន្តបន្ទាប់ ដោយបានវាយតម្លៃថាបញ្ជីបោះឆ្នោតរបស់ គ.ជ.ប ឆ្នាំ២០២១ មានភាពពេញលេញ ៩៨.៦៧% និងបញ្ជីបោះឆ្នោតឆ្នាំ២០២២ អាចទទួលយកបាន ហើយបញ្ជីបោះឆ្នោតឆ្នាំ២០២៣ ខុមហ្វ្រែលនៅតែរកឃើញថាមានភាព

វិជ្ជមានដដែល។ ផ្អែកតាមលទ្ធផលសង្កេតនេះ បានបង្ហាញថាបញ្ជីបោះឆ្នោតផ្លូវការចុងក្រោយរបស់ គ.ជ.ប នៅតែមានគុណភាពខ្ពស់ មានភាពពេញលេញ ត្រឹមត្រូវ និងមានបច្ចុប្បន្នភាព សម្រាប់បម្រើឱ្យការបោះឆ្នោតជាសកលនាពេលខាងមុខស្របតាមការកំណត់នៃច្បាប់។

អាស្រ័យហេតុនេះ សូម **លោកនាយករដ្ឋមន្ត្រី** ជ្រាបតាមការគួរ។

*សូមជូនភ្ជាប់មកជាមួយនូវ ៖ តារាងលទ្ធផលនៃការសិក្សាលើឈ្មោះអ្នកបោះឆ្នោត ចំនួន ១៤ ឈ្មោះ ដែលខុមប្រែហូលបានរកឃើញថាស្ទួន ចំនួន ១ (មួយ) ច្បាប់។*

ថ្ងៃ ច័ន្ទ ៣កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
**អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស**
នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

## តារាងលទ្ធផលនៃការសិក្សាលើឈ្មោះអ្នកបោះឆ្នោត ចំនួន ១៤ឈ្មោះ ដែលខុមប្រៀលបានរកឃើញថាស្ទួន

| ល.រ | ល.រ ក្នុងបញ្ជី | កូដខេត្ត | កូដឃុំ | កូដការិ. | ប្រភេទអ.ខ | លេខ អ.ខ | នាមត្រកូល | នាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អត្តលេខ | ស្ថានភាព | បញ្ហា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 450 | 10 | 017 | 0191 | អ.ខ ទី៣ | 070002503 | ស្នាន | វ៉ានី | ប្រុស | 10/10/1972 | 100170191 | ស្ទួន | ខ្មៅដៃតែមួយ |
| 2 | 314 | 12 | 076 | 1223 | អ.ខ ទី៣ | 070002503 | ស្នាន | វ៉ានី | ប្រុស | 10/10/1972 | 120761223 | | |
| 3 | 460 | 12 | 102 | 1718 | អ.ខ ប្រភេទថ្មី | 100732066 | ហ្វូច | វិចិត្រ | ប្រុស | 22/6/1990 | 121021718 | ស្ទួន | ខ្មៅដៃតែមួយ |
| 4 | 425 | 12 | 102 | 2190 | អ.ខ ប្រភេទថ្មី | 100732066 | ហ្វូច | វិចិត្រ | ប្រុស | 22/6/1990 | 121022190 | | |
| 5 | 276 | 07 | 036 | 0366 | អ.ខ ទី១ | 110252896 | ម៉ាក | កែវ | ប្រុស | 6/6/1986 | 070360366 | មិនស្ទួន | មនុស្សពីរផ្សេងគ្នា |
| 6 | 45 | 07 | 045 | 0502 | អ.ខ ទី៣ | 110252896 | ខាត់ | ម៉ៅ | ប្រុស | 6/6/1986 | 070450502 | | |
| 7 | 203 | 07 | 057 | 0611 | អ.ខ ទី២ | 110387308 | លន | ង៉ា | ស្រី | 10/2/1986 | 070570611 | មិនស្ទួន | មនុស្សពីរផ្សេងគ្នា |
| 8 | 209 | 07 | 057 | 0613 | អ.ខ ទី៣ | 110387308 | លន | ង៉ា | ស្រី | 10/2/1986 | 070570613 | | |
| 9 | 49 | 08 | 083 | 0886 | អ.ខ ទី៣ | 050147835 | ច្រឹក | ជា | ស្រី | 12/12/1980 | 080830886 | មិនស្ទួន | មនុស្សពីរផ្សេងគ្នា |
| 10 | 62 | 14 | 078 | 1210 | អ.ខ ទី១ | 050147835 | ច្រឹក | ជា | ស្រី | 12/12/1980 | 140781210 | | |
| 11 | 167 | 20 | 080 | 0920 | អ.ខ ទី៣ | 090564951 | ចៅ | ផាន្នី | ស្រី | 12/1/1995 | 200800920 | មិនស្ទួន | មនុស្សពីរផ្សេងគ្នា |
| 12 | 526 | 20 | 080 | 0920 | អ.ខ ទី៣ | 090564951 | ឡុង | ហ៊្សនស្រី | ស្រី | 12/1/1995 | 200800920 | | |
| 13 | 160 | 25 | 006 | 0106 | អ.ខ ទី៣ | 060946987 | ទន់ | សេងហុង | ប្រុស | 5/3/1985 | 250060106 | មិនស្ទួន | មនុស្សពីរផ្សេងគ្នា (បងប្អូនភ្លោះ) |
| 14 | 161 | 25 | 006 | 0106 | អ.ខ ទី១ | 060946987 | ទន់ | សេងប៉ាង | ប្រុស | 5/3/1985 | 250060106 | | |

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤

**បានឃើញ និងឯកភាព**
**អគ្គនាយក**

**គុប_ឫទ្ធី**

**ប្រធាននាយកដ្ឋាន**

**ស៊ិន_សាវតា**